Khmer Story Lovers


# បញ្ហាមរណៈ

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិ ផ្ទះលេខ ២៩ ផ្លូវលេខ ២៧៥ ទីឡូត៍លេខ ២៩៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —


## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ




អ្នកប្រែសម្រួល: អ.គឹមសាន ]



តម្លៃ ៣ រ ០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

« មាតុភូមិ »

ភ្នំពេញ

លេខ ២០


កាស៊ីវពោលបន្តថា:

-លោកយាយ ! បងខាងណោះថាគាត់មិនគួរតែជួប លោកគ្រូពាយទេ !

យាយស៊ីបែរសម្លក់ខាង ហើយបែរទៅប្រាប់នាយ:

– ល្អ ! ឯងចាប់ហាត់មើលតើគួរតែប៉ុណ្ណា ?

ប្រាកាពយល់ថា ជួនចាស់ពោលចំអកឲ្យហើយ ក៏ក្រហមមុខទាំង ដើរទៅកាច់មែកឈើបួកស្លឹកបោល អស់ថ្មៀវ ហើយបញ្ចេញក្បាច់ចាក់តាមសិស្សគ្រូចក កក ៗ យាយសាវល្អយសើចក្អាកក្អាយ:

-ស្បៀតទីមួយខុសស្រឡះហើយកាច្រមក់ ៗ

ស៊ីផងនាងកាន់តែក្រហមមុខ, ចម្លាក់មែកឈើបោលក្វាម ៗ យាយស៊ីតៀន :

-ហាត់ទៀតមើល ! បង្ហាញយើងមក តើយុទ្ធសិល្បៈក្រុមក្តិចកកកួតត្រឹមណា ?

មាកាកពាលៀនណាស់ ប្រុងលោះមែកឈើគ្រវែងទៅឆ្ងាយ តែលុះនាយងើកមើលមុខកាស៊ីវ ឃើញនាងញញឹមស្រស់តែសញ្ញាមើលងាយ ៗ ចំអកសោះ នាយលែងខឹង យារមែកឈើចាក់ក្បាច់ទៀតក្វាម ៗ ម្តងនេះនាយខ្លាចខុសផង, ខ្លាចជួនចាស់ពោលចំអក ឬ បន្ទោសផងក៏ចំនួនស្មារតី បញ្ចេញស្បៀតម្តងមួយ

យ៉ាងយកចិត្តទុកដាក់ ។ ហាក់បណ្ដើរ នាយទឹកដល់ការប្រយុទ្ធជាមួយអ្នកស្រីទេយ្យកុងខ្ចុម កញ្ចាស់ផង ។ បានប្រហែលជាបងស្មៀតនាយបញ្ចេញកាយវិការរឹតតែល្អស្អាត ហើយកម្លាំងខ្យល់ បក់បេញមកខ្លាំងជាងមុន ។

ដំបូងជូនចាស់ញញឹមក្នុងចិត្ត មាត់អោយប្រមាថណាស់ណាស់, កាស៊ីវក៏ញញឹមស្ងួតបួតរង់ចាំមើល ដែរ ។ ក្រោយមកជូនចាស់ក្មេងរៀនចំអកត្រឡប់ជាញញឹមអោយស្ងោះ ចាប់ផ្ដើមសើចសើរ សើរទៅវិញ ។ ជីជូនងិងទៅមើលមុខគ្នាមិនចេញស្ដី, ស៊ីផានគិតតែថ្លង់ស្មារតីហាក់គុន ដាវតាំងពិតបើបតីខាងក្រុមភ្នំទឹកកក ( នាយបាំតៃពុកបប្រាំពីរទេ, ប្រាំស្មៀតទៀតនាយក្មេង ស់ ) ។ សាបុះសាឡើង បញ្ជាក់ខ្លាំងការបេះបាំស្ងាត់តែមិនទាន់បានរណាតប្រែគម្រង់តខ្យល់ណានាំ ថែមទៀតឡើយ ។ ជីជូនងិងទៅអង្គុយមើលចំហមាត់ងឹកថា កម្លាំងកាយមាណពរូបនេះស្អុក ស្អុកណាស់កម្រកេនរណាបៀបផ្ទឹមបាន ។

ពេលនោះស៊ីផានត្រូវងំមែកឈើបោលពោលថា :

–ខ្ញុំល្ងង់ណាស់, ប៉ុន្មានថ្ងៃសោះក្មេងអស់ខ្លះហើយ ... សូមកុំសើចកុំយំអី ។

ជូនចាស់សួរ :

–ឯងថាឃើញសិស្សភ្នំទឹកកកប្រកួតគ្នាឯងល្អបមើលឬ ?

មាណពក្រហមមុខ :

–បាទ ។ ខ្ញុំដឹងថាល្អបមើលគេមិនល្អទេ, តែគុនដាវពួកគេល្អប្រពៃណាស់ បានជាខំចង់ចាំ ទុកហាត់ខ្លួនឯង ។

ជូនចាស់ពោលបន្ត :

– គ្រាន់តែលបមើលគេម្ដង ឯងបញ្ចេញស្មៀតតាមគេបានប៉ុណ្ណឹង ឃើញថាមានប្រាជ្ញាជំពូល ទៅហើយ ។ ឯងច្បាស់ជាហាត់គុនកាំបិតរបស់ក្រុមព្រះកាចិរ្យបានស្អាតពុំខាន ។ នែ ! សុំ យើងធ្វើគ្រូទៅ ។

កាស៊ីវពោលកាត់ :

– លោកយាយ , ធ្វើអីចង់មិនស្រួលទេ ។

– ម៉េចបានជាមិនស្រួល ?

នារីក្រហមមុខ :

– បើអ៊ីចឹង ខ្ញុំត្រូវហៅគាត់ថា « លោកគ្រូ » , ខ្ញុំត្រូវតាមជាន់គាត់មួយថ្នាក់ហើយ ...

ដូនចាស់ថ្ងោះទឹកមុខ:

– គ្រូគឺគ្រូទៅ , មានចាស់អី ? បើកញ្ញាស់ទីនមិនហួសប្អូនមកតាមតាទៅយើងដល់ទីនេះ, យើងលែងបបួលគ្នាលោតទឹកសម្លាប់ទៀតហើយ ។ យាយកែវឃើញមធ្យោបាយតែមួយគឺ បង្ហាត់បង្រៀនការអន្សមធំឲ្យចេះគុនកាំបិតស្នាក់ដើម្បីទប់ទល់នឹងកញ្ញាស់ទីនមួយគ្រាសិន ។ ព្រោះថ្នាក់នៅជិតបង្អើយឯនការិយាល័យតែគិតខ្ពស់ចាបផ្ញើ ។ អី! ការអន្សមធំ! ថ្ងៃនេះយើងគិតផ្ដើមបង្កើតក្រុមបក្សមួយហើយ , ឯនជាសិស្សទីមួយខាងក្រុមព្រះអាទិត្យ , យល់ព្រមទេអាប្រមក់ ?

មាណពជាមនុស្សស្លូតបូត ចង់សុំយាយសាវណ្ណយធ្វើគ្រូណាស់ តែនាយឮអាស៊ីវថាមិនចង់ហៅលោកគ្រូក៏អេះអុញមិនចេញស្ដី ។ ដូនចាស់តឿន :

–នែឆាប់លុតជង្គង់សំពះយើងមក ! ឯនក្លាយជាសិស្សសំណប់នៃក្រុមព្រះអាទិត្យភ្លាម ។ យើងជាអ្នកផ្ដើមបង្កើតក្រុមព្រះអាទិត្យ, ឯនជាសិស្សច្បងជំនាន់ទីពីរ ។

នាងក្រមុំស្រាប់តែនឹកឃើញរឿងមួយ ពោលដោយរីករាយថា:

– លោកយាយ , ខ្ញុំសុំជូនពរលោកយាយដែលបានបង្កើតក្រុមនេះ ។ លោកបង , សូមសំពះលោកយាយធ្វើគ្រូចុះ , ខ្ញុំមិនមែនសិស្សក្រុមព្រះអាទិត្យទេ ម្ល៉េះហើយខ្ញុំមិនបាច់ពិបាកហៅលោកបងថា «គ្រូ» ដែរ ។

ដូនចាស់ចង់បានសិស្សឆាប់ ឥតរវល់ពិចារណាសំដីចៅស្រីទេ , គាត់តឿន :

– លុតជង្គង់សំពះយើងប្រាំបីដងឆាប់ឡើង !

ស៊ីផានឃើញអាស៊ីវយល់ព្រមហើយ ក៏ម្នាលុតជង្គង់សំពះយាយសាវណ្ណយប្រាំបីដងដោយរីករាយ ។ ដូនចាស់ញញឹមបិទមាត់មិនជិតពោលថា:

– ល្អណាស់សិស្សសំណប់ ។ ចាប់ពីថ្ងៃនេះទៅយើងជាក្រុមគ្រួសារតែមួយ ។ ក្រុមព្រះអាទិត្យត្រូវមានឋានៈខ្ពង់ខ្ពស់មានកេរ្តិ៍ឈ្មោះល្បីល្បាញជាងគេក្នុងពិភពគុន ។ ឯនត្រូវយកចិត្តទុកដាក់ខំហាត់រៀនយុទ្ធសិល្បៈឲ្យមែនទែន ។ គឺឯននេះហើយដែលមានភារៈលើកស្ទួយកិត្តិយសក្រុមព្រះអាទិត្យណា៎ ! ការអន្សមធំ ...

អាស៊ីវខ្ទប់មាត់សើច៖

- ទេ លោកយាយនាយក្រុមព្រះអាទិត្យអើយ ! សិស្សច្បងជាអ្នកខ្លាំងពូកែប៉ុណ្ណឹងដែរ ប្រើរហស្សនាមហ្នឹងដូចជាមិនសូវពីរោះសោះ !

ដូនចាស់យល់ស្រប៖

- ត្រូវមែន ! ឯងឈ្មោះអ្វី ប្រាប់គ្រូមក, កុំខ្មាសអៀន ។

- ចាស ៗ.. ម៉ែខ្ញុំហៅថាអាក្អែកតូច, ពួកក្រុមឈានល្បែងហៅខ្ញុំលោកនាយក្រុមស៊ីផាន ។ តាមពិតខ្ញុំមិនមែននាយក្រុមទេ, ខ្ញុំឥតស្គាល់ឈ្មោះ មែនតែម្តង ។

ដូនចាស់គ្រហឹម៖

-ក្អែកតូចយ៉ាងម៉េច ? ម្តាយឯងមែនបក្សីលើលោកទេដឹង បានជាហៅកូនដូច្នេះ? ឥឡូវគ្រូគេឈ្មោះឲ្យឯងគេចុះ ។ សិស្សជំនាន់ទីពីរ ត្រូវមានត្រកូលដូចយើងគឺស៊ី, ត្រូវយកអក្សរដើមជាកណ្តាលស្លាក? អូ! សិស្សក្នុងកកឈ្មោះចាយវាន់ជាន, ហ្វាំងវាន់លី, ទិនវាន់ផុង ។ល។ វាន់ប្រែថាមួយម៉ឺន ។ សិស្សក្រុមព្រះអាទិត្យត្រូវខ្លាំងពូកែជាងពួកនោះមួយម៉ឺនដង ! បើគេដាក់វាន់, យើងដាក់ឈ្មោះឯងថា «យី» ។ ណ្ហើយ ! ដាក់ឈ្មោះឯងថាស៊ុយីគាវចុះ ។

កូនមួយជីវិតនេះមាណពមិនដែលមានឈ្មោះទីងគេឲ្យពិតប្រាកដទេ ។ គេហៅនាយថា អាក្អែកតូច ឬ អាអន្ទេរធំ នាយឥតខ្វល់ទេ ។ ពេលនេះដូនចាស់ដាក់ឈ្មោះ ស៊ុយីគាវ ហើយទោះមិនដឹងថា «យី» មានន័យថាដប់ពាន់ ឬ «គាវ» ថា កាំបិត ក៏នាយឥតខ្វល់ទៀត ។ បំណែកដូនចាស់រីករាយណាស់ពោលភ្លាម៖

-គុនកាំបិតខាងក្រុមព្រះអាទិត្យនេះគ្រូបានបង្កើតរូបស្រេចបាត់ហើយ តាំងពីប្រាំមួយឆ្នាំមុនម្ល៉េះ ។ ប៉ុន្តែអ្នកហាត់រៀនហ្វឹកហ្វឺនយុទ្ធសិល្បៈនេះ ត្រូវមានកម្លាំងកាយស្អុយស្អប់ដូចឯង ទើបហាត់កើត ។ ថ្ងៃមុនយើងជួបកញ្ចាស់ទីងមិនហួសប្អូនលើទន្លេឈានការ វាបានបបួលយើងទៅកោះខ្យងទៀតដើម្បីប្រកួតប្រជែងគ្នាសាកមើល ។ យាយចង់ស្គាល់ថាដែលដែរបានជាបបួលអាស៊ីវហាត់តាមគម្ពីរបិសាចនោះទៅ ។ ទេ ! បើយាយរកបហាត់គុនកាំបិតបាន, កុំថាឡើយត្រឹមទីងមិនហួសប្អូនដែលជាបិសាច សូម្បីអ្នកក្លាហានជើងឯកក្នុងពិភពគុនក៏ប្រហែលគ្មានផ្លូវទប់ទល់នឹងយើងបានដែរ ។ ចាំ ពេលនោះអាស៊ីវស្ទះដង្ហើម, យើងស្ទុះទៅជួយដោយភ័យស្ទើរស្រាប់តែ

រងគ្រោះតាំងពីដូនតាំងទៅដូចឯងឃើញស្រាប់ ។ ពេលនេះក្លាយជាមនុស្សពិការទៀត ! ហ៊ឺ...

ដូនចាស់នេះមានចិត្តស្មោះត្រង់ណាស់, ឥតបេះលាក់អាថ៌កំបាំងទេ ។ គាត់រៀបរាប់ទៀតថា:

-សំណាងល្អណាស់បានជួបឯងនៅក្មេងមានកម្លាំងស្ដុកស្ដម្ភស្រាប់ ។ នេះជាលក្ខណៈសំខាន់សម្រាប់ហាត់គុនដាវកាំបិតរបស់យើង ។ គុនកាំបិតមិនដូចគុនដាវទេ, ឯងត្រូវហ័សលើសល្បឿនហើយ យារដៃម្តងៗ ឲ្យខ្លាំងឲ្យសាហាវ ... ប្រើមែកឈើហាត់មិនស្រួលទេ ។ ឯងទៅរកកាប់មែកណាធំជាងនេះមក !

មាណពទទួលបញ្ជាហើយរាក់ខ្លួនប្រុងទៅកាប់មែកឈើធំ ស្រាប់តែក្រឡេកឃើញកាំបិតប្រេះបាប់មួយកញ្ចាស់តែ ដោតផ្តិតលើដើមឈើមួយ ។ គឺជាកាំបិតកាប់ស្រុសគ្មានដងទេ, មុខវាតែមច្រើនអន្លើ ដូចជាគ្មានប្រយោជន៍អ្វីទេ បានជាគេបោះបោលដូច្នេះ ។ មាណពដកកាំបិតមកថ្លឹងមើលនឹកថា នោះប្រេះបាប់ហើយ តែបរធិញតុញក៏ធ្ងន់ជាងមែកឈើ ហើយជាកាំបិតដែរម៉្លេះហើយនាយរកឈើមួយដុំដោតជំនួសដងកាំបិត ហើយត្រឡប់មកកាន់រូងភ្នំវិញភ្លាម ។ ដូនចាស់សាវល្អយព្រមតាំងចៅស្រី ឃើញកាំបិតកញ្ចាស់ ក៏រស់សំណើចព្រមគ្នា ។ នាងក្រមុំពោលកំប្លែង :

-យាយអ្ហា ! ថ្ងៃនេះធ្វើបុណ្យសម្ពោធក្រុមព្រះអាទិត្យទទួលសិស្សជំបូងផង, ប្រើកាំបិតចិត្រនេះបង្ហាត់បង្រៀនសិស្ស ដូចជា ... ដូចជាមិនសូវថ្លៃថ្នូរទេដឹង ?

ដូនចាស់ប្រកែក :

-ម៉េចឯងថាមិនថ្លៃថ្នូរ ? ប្រយ័ត្នណា ! ថ្ងៃមុខថ្ងៃក្រោយ ក្រុមព្រះអាទិត្យមានឈ្មោះល្បីល្បាញសុសសាយពេញពិភពគុន ត្រូវនឹកដល់ ... កាំបិតចិត្រនេះជាដាច់ខាត !

ពោលដល់ពាក្យ «កាំបិតចិត្រ» គាត់សើចស្ញាញជាមួយចៅស្រី ។ បន្ទាប់មកគាត់ពោលទៅកាន់មាណព :

-ឯងចាំឲ្យច្បាស់ណា ! ស្នៀតគុនកាំបិតទីមួយមានឈ្មោះថា «បើកទ្វារទទួលចោរ» ។

យាយសាវល្អយរើសមែកឈើខ្ចីមួយកាន់តំណាងកាំបិតបង្ហាញស្នៀតទីមួយដល់មាណពជាសិស្សព្រមទាំងបញ្ជាក់ :

-យើងមិនសូវមានកម្លាំងទេ, ឯងត្រូវបញ្ចេញកាយវិការឲ្យរហ័សជាងយើងទើបល្អ ។

មាណពគាត់គាំបិតកាប់កុសយារតាមដូនចាស់រលាស់ខ្ទាប់ៗអស់ចំហឹង ។ ដូនចាស់សរសើរ:

-ល្អ! បើហាត់ទៅស្ទាត់ជាងនេះឯងត្រូវធ្វើឲ្យរហ័សណាំ! ស្នៀត "បើកទ្វារទទួលចោរ"នេះ សំរាប់បង្ក្រាបស្នៀត "ទុនក្បាលទទួលភ្ញៀវ" របស់ក្រុមដុំទឹកកក ។ ក្រុមដុំទឹកកកធ្វើឫកជាតំណាប់ភ្ញៀវបន្លំភ្នែកគេ, ចំណែកពួកយើងត្រូវបើកទ្វារទទួលចោរត្រង់ ៗ តែម្ដង, ព្រោះយើងហៅគេជាភ្ញៀវ តែក្នុងចិត្តយើងចាត់គេទុកជាចោរស្រេចទៅហើយ ។

ស្នៀតទីពីរ គឺ "បុប្ផាខែប្រាំង" សម្រាប់បង្ក្រាបស្នៀត "បុប្ផាស្គុសស្គាយ" របស់ក្រុមដុំទឹកកក ។ ស្នៀតរបស់ពួកគេអាចបញ្ចេញផ្កាទឹកកកម្ដងប្រាំមួយឬប្រាំពីរទង, ប៉ុន្តែយើងចង់ឲ្យផ្ការីកអស់នោះប៉ះរដូវប្រាំងរាំងភ្លៀងម្ដង ដើម្បីធ្វើឲ្យផ្កាទឹកកកអស់នោះរុះរោយគ្មានសល់ ។

ស៊ីផាន ធ្លាប់ឃើញម៉ាយវ៉ាន់ផានសំដែងស្នៀតបុប្ផាស្គុសស្គាយនៅក្រុមឈានល្អម្ដងឃើញតែពន្លឺសព្រាតៗ ពោកខ្យល់វឹបៗ មើលមិនទាន់ ។ រីស្នៀតបុប្ផាខែប្រាំងវិញគឺរហ័សណាស់ដែរ មួយដង្ហើមត្រូវលើកគាំបិតកាប់ទៅលើបីដង, ក្រោមបីដង, ឆ្វេងស្ដាំបីដងៗដូចគ្នា ដោយកម្លាំងច្រើនមហិមារំលាយស្នៀតដាវសត្រូវឲ្យវិនាសប្រៀបដូចរដូវប្រាំងស្រោចស្រប់លើបុប្ផាបណ្ដាល ឲ្យស្លូតក្រញង់ ។ ស្នៀតទីបីឈ្មោះថាទ័ពបង្ក្រាបសេះ សម្រាប់រំលាយស្នៀតទ័ពសេះចេញទៅខាងក្រុមដុំទឹកកក ។ ស្នៀតទីបួនគឺ ខ្សាច់លេចបាតសមុទ្រសំរាប់រំលាយស្នៀតខ្យល់បក់វាលខ្សាច់, ស្នៀតទីប្រាំឈ្មោះព្រានព្រៃកាប់អុសរំលាយស្នៀតមែកឈើខ្ទាត់ខ្ទង, ទីប្រាំមួយឈ្មោះ ញូកវែងមុខស្រួចសំរាប់បង្ក្រាបស្នៀតហ្វូងត្រីក្នុងទឹក ។

ស្នៀតគុនគាំបិតរបស់ដូនចាស់សុទ្ធតែមានឈ្មោះប្លែកៗ មានន័យប្រឆាំងនឹងស្នៀតដាវខាងដុំទឹកកកទាំងអស់ហើយមានឥទ្ធិពលខ្លាំងក្លាផង ។ ស៊ីផានមិនបេះអក្សរមួយតួក៏ដូចមិនយល់ន័យ ហើយមិនចាំឈ្មោះស្នៀតអស់នេះដែរ ។ តែនាយយល់ថាមិនបាច់ស្គាល់ឬចាំឈ្មោះវាទេ , គ្រាន់តែធ្វើគ្រាប់តាមលោកយាយជាគ្រូឲ្យបានត្រឹមត្រូវជាការស្រេច ។ យាយសាវណ្ណួយពន្យល់បណ្ដើរកាច់ក្បាច់បង្ហាញស្នៀតយឺតៗបណ្ដើរ ។ កាលណាមាណពធ្វើមិនត្រូវគាត់ជួយកែតម្រង់និងពន្យល់ថែមភ្លាម ។ គាត់បង្ហាញបានតែរបៀបបីស្នៀតក៏អស់កម្លាំងល្ហិតល្ហៃប្រឹងបិទភ្នែកសម្ងំបណ្ដាយឲ្យមាណពហាត់ម្នាក់ឯងសាចុះសាឡើង ។

Khmer Story Lovers



ប្រហែលកន្លះម៉ោងក្រោយ គាត់បង្រៀនថែមបានដប់ប្រាំបីស្នៀតទៀត រហូតពេលព្រលប់គាត់បង្ហាត់គ្រប់ចិតសិបពីរស្នៀតស្រេច ។ ទីបំផុតដូនចាស់ឲ្យមាណពហាត់សារឡើងវិញតាំងពីដើមដល់ចប់ ទើបពោលបង្ហើយ :

– ខាងក្រុមក្តុំទឹកកកមានគុនដាវចិតសិបពីរស្នៀត ។ ក្រុមព្រះរាជវាំងយើងមានគុនកាំបិតចិតសិបពីរស្នៀតដែរ តែត្រូវឈ្នះក្រុមក្តុំទឹកកកមួយកំរិត ទើបយើងសុខចិត្ត ។ ដូច្នេះត្រូវមានចិតសិបបីស្នៀតជាចាំបាច់ ទើបបង្ក្រាបគុនដាវទាំងចិតសិបពីរបាន ។ ឯងមើលឲ្យច្បាស់ណា !

ពោលហើយគាត់លើកមែកឈើខ្ពស់ផុតដៃសំពងពីលើមកអស់ទំហឹងព្រមទាំងពោលបញ្ជាក់ :

– នៅពេលចង់ប្រើស្នៀតនេះ ឯងត្រូវលោតខ្ពស់ផុតដៃហើយទម្លាក់ខ្លួនមកវិញឲ្យលឿន ។

បន្ទាប់ពីនោះ ដូនចាស់បង្ហាត់បង្ហាញរបៀបប្រើកម្លាំងកាយ, របៀបហក់លោតនិងស្ទាក់កាប់សត្រូវតាមចន្លោះនានាមិនឲ្យរត់រួចរោះ ។ មាណពសញ្ជឹងគិតមួយស្របក់ទើបស្ទុះក្រោកធ្វើតាម ។

ឮសូរវ៉ូៗ ! រាងកាយនាយប៉ុនខ្ពស់ដូចស្រាលស្លឹក, ដល់កាប់សំពងចុះមកវិញនាយបញ្ចេញខ្យល់ដៃឮវ៉ូៗ ដូចខ្យល់ព្យុះបក់ស្លឹកឈើព្រមទាំងធូលីក្ដួចវិលខ្វាល់ ។

សំដែងស្នៀតនេះរួចនាយ ទម្លាក់ជើងដល់ដីឈរស្ងៀម ។ ដល់បែរមើលមុខយាយសាវ ឈ្លួនឃើញស្នាំង ហើយនាងក្រមុំស្រក់ទឹកភ្នែកតក់ៗ ដូចជាព្រួយ ឬសោកស្ដាយអ្វីមួយ, នាយធ្ងល់ណាស់ សួរដោយញញើតញញើម :

– ស្នៀត ... ស្នៀតចុងក្រោយនេះខ្ញុំធ្វើខុសហើយឬ ?

ដូនចាស់ពោលតបថា :

– ត្រូវហើយ ។

គាត់ឈប់បន្តិចទើបពោលត:

– ស្នៀតមួយនេះមានឥទ្ធិពលហួសប្រមាណ , កុំប្រើផ្ដេសផ្ដាសណា ប្រយ័ត្នស្លាប់មនុស្សដោយភ័ន្តច្រឡំ ។

– បាទ ៗ ខ្ញុំដឹងហើយ , មនុស្សល្អមិនត្រូវស្លាប់ទេ ។

ពេលនេះ មាណពដេកស្រមៃឃើញតែស្នៀតគុនកាំបិតចំនួនចិតសិបបី, ដល់ដេកលក់យល់សប្តិ

ឃើញទៀត ។ នាយឥតក្រែងរែងថា មិនមានសត្រូវតាមកេដល់នេះឡើយ ។ កោះផ្សែងខ្មៅគួចហើយព្រៃរុះក្រាស់ឃ្មឹក មានប្រកខ្ចាត់ខ្ចៃ មិនងាយរុករកមែន ទើបក្រុមប៉ាយរ៉ាត់ជាន់រកផ្លូវមិនទាន់ប្រទះ ។

ថ្ងៃនេះ ស៊ុនណានក្រោកពីព្រលឹមហាត់ស្ទៀតគុនកាំបិតតាំងពីដើមដល់ស្ទៀតទីចិតសិបពីរ ។ ទើបបញ្ចប់ដោយលោតឡើងលើកាប់មកក្រោមរឹបខ្លាំងជាងថ្ងៃមុនកប់រយដង ។ ខណៈនោះអាស៊ីវស្រែកពីក្រោយខ្នង :

– អរុណសួស្ដីលោកបងស៊ុ !

ស៊ុនណានងាកទៅឃើញនាងក្រមុំឈរផ្អែកមាត់រូងបើកភ្នែកខ្មៅក្រឹបសំឡឹងមក ។ នាយសើចតប :

– អរុណសួស្ដី !

អាស៊ីវមុខក្រហមបន្តិចពោល :

– ខ្ញុំចង់ដើរទៅព្រៃឯនាយបន្តិចក្រែងស្រួលខ្លួន ។ បងជូនខ្ញុំទៅបានទេ ?

– បាទ នាងស្រាយជីពចរអស់ហើយ, ដើរកំសាន្តកាយជួនខ្លះត្រូវណាស់ ។

អ្នកទាំងពីរដើរទន្ទឹមគ្នាផុតពីរូងជួបន្តិចទើបដល់ព្រៃ ។ ទីនេះមានផ្សែងខ្មៅស្អុំដូចចុះអព្ទមើលអ្វីឃើញស្រពិចស្រពិលព្រោះថ្ងៃមិនទាន់រះផុតចុងឈើ ។ កម្លោះក្រមុំដើរស្ងៀមស្ងាត់ជាន់ស្លឹកឈើឆាប់ឮព្រេបៗ ។ មួយសន្ទុះស្រាប់តែស៊ុនណានឮសម្លេងយំខ្សឹកខ្សួលក្បែរខ្លួន ។ នាយឃើញអាស៊ីវយំរហាមទឹកភ្នែកហូរស្រោចស្រប់ថ្ពាល់ដ៏ផូរផង់, នាយភ្ញាក់ព្រើតសួរភ្លាម :

– អ្នកនាងអាស៊ីវ, ហេតុអីបានជាយំអ៊ីចឹង ?

អាស៊ីវមិនតប, ដើរទៅមុខឱបដើមឈើមួយយំខ្សឹកខ្សួលតទៅទៀត ។ ស៊ុនណានដើរទៅជិតសួរទៀត:

– ហេតុអីបានជាអ្នកនាងយំ ? លោកយាយបន្ទោសឬ ?

អាស៊ីវគ្រវីក្បាល, អ្នកកម្លោះសួរបញ្ជាក់:

– អ្នកនាងមិនស្រួលខ្លួនទេដឹង ?

អាស៊ីវគ្រវីក្បាល ។ មាណពសួររកដើមហេតុប៉ុំពីរប៉ុំប៉ាយ៉ាង អាស៊ីវគ្រវីក្បាលរហូត

ធ្វើឲ្យនាយរឹតតែឆ្ងល់តាល់ច្រកឈរសម្លឹងមុខនាងនៅស្ងៀម ។ ព្បិតនាយធ្លាប់ស្គាល់ស្ត្រីចិត្តខ្លាំងស្មោះត្រង់ ចូលាយឬចិត្តទៅគោរពបូជាម្ដាយនាយ, តាយាន, ទីងតុង ។ល។ ដែលនឹកឃើញអ្វីនិយាយនោះភ្លាម ៗ , សូម្បីតែអ្នកស្រីវុនយូ ដែលមានទឹកមុខស្រគត់ស្រគំក៏ជានារីក្លាហានកាន់ដាវត្រាច់បក្ខុនពិតតគុនដែរ ។ ពេលនោះឃើញកាស៊ីវអឹមអៀមតាមរបៀបស្រីក្រមុំគ្រប់លក្ខណ៍ដូច្នេះ នាយមិនបេះស្មានឡើយ ។ ប៉ែនាងមិនប្រាប់ទុក្ខសោក នាងយំកាន់តែខ្លាំង នាយភ័យកាន់ខ្លាំងដែរ; ម្ល៉ោះហើយនាយសួរដដែល ៗ :

– មានរឿងអី, និយាយប្រាប់ខ្ញុំផងបានទេ ?

កាស៊ីវនៅតែយំអណ្ដឹតអណ្ដក តបជាប់ ៗ :

– មានរឿង...ហ៊ឺ...ហ៊ឺ...មកពី...មកពីបងចាំងអស់ហ្នឹង .. ម៉េចបងនៅសួរខ្ញុំទៀត ?

មាណពភ្ញាក់ព្រើតនឹកថា យើងធ្វើអីខុសបានជានាងយំ ?

ស៊ីផានគោរពនារីស្លូតបូតនេះតាំងពីជួបគ្នាលើកដំបូងម៉្លេះ ។ នាយល្ងង់ខ្លៅណាស់ កាលបើឮនារីពោលដូច្នេះក៏យល់ថា ខ្លួនមានប្រព្រឹត្តអំពើអ្វីមួយខុសចិត្តគេមែន ទើបពោលញ៉ែរៗ :

– អ្នកនាង . . . កាស៊ីវ . . . សូមជួយប្រាប់ខ្ញុំផងមើល នាងពិបាកចិត្តរឿងអី, ព្រោះខ្ញុំល្ងង់ណាស់ឥតដឹងខ្លួនទេ ។

កាស៊ីវងាកមុខមក, ទឹកភ្នែកហូរហាម:

– យប់មិញខ្ញុំយល់សប្តិអាក្រក់ណាស់,ខ្ញុំភ័យណាស់ព្រោះឃើញបង . . . បងកាចជាមួយខ្ញុំពេក...

ពោលដល់នេះនាងយំរឹតតែខ្លាំងឡើង ។ មាណពស្ទុះទៅជិតសួរសន្ធើញ :

– ខ្ញុំធ្វើអីនាងខ្លះ ?

– ខ្ញុំឃើញ .. ខ្ញុំយល់សប្តិឃើញបងបញ្ចេញស្នៀតទីចិតសិបបីនៃក្រុមព្រះកពិត្យ... បងលោតឡើងលើខ្ពស់ ហើយកាប់សំពងខ្ញុំចាល់តែស្លាប់មួយរំពេច ។

ស៊ីផានស្រឡាំងកាំងលើកដៃគក់ទ្រូងឱបៗ:

– អាក្រក់មែន ! អាក្រក់ណាស់ ! ខ្ញុំធ្វើឲ្យនាងភ័យរស់មួយយប់ ។

កាស៊ីវសើចទាំងទឹកភ្នែក ;

– បងស៊ី ... នេះជាការយល់សប្តិទេ , មិនគួរបន្ទោសបងឡើយ ។

ស៊ីផានសម្លឹងផ្កាលំផូរផង់ដែលក្រហមប្រៀងៗ មានតំណក់ទឹកភ្នែកហាក់ដូចបុប្ផាពេលព្រឹកដក់ទឹកសន្សើមរីកស្រស់ប្រិមប្រិយ, នាយដាប់ដំពាក់ចិត្តឈរមើលភ្លេចខ្លួន ។ អាស៊ីរអៀនខ្មាសងាកមុខបន្តិចទឹកភ្នែករមៀលធ្លាក់ចុះបាត់ទើបពោល:

-ខ្ញុំធ្លាប់យល់សប្តិតណាស់ បានជាបារម្ភខ្លាច មានថ្ងៃណាមួយបងប្រើស្នៀតទីចិតសិបបីសម្លាប់ខ្ញុំមែនណា៎ !

ស៊ីផានគ្រវីក្បាលញាប់ស្អក :

-ទេ ! ទោះបីយ៉ាងណាក៏ខ្ញុំមិនសម្លាប់នាងដែរ, ខ្ញុំមិនអាចចិត្តឡើយ, សូម្បីនាងចង់សម្លាប់ខ្ញុំក៏ខ្ញុំ... ខ្ញុំមិនតបដែរ ។

អាស៊ីរសួរដោយឆ្ងល់:

- បើខ្ញុំសម្លាប់បង, ហេតុអីបងមិនតបត ?

មាណពអេះក្បាល :

-ខ្ញុំ... ខ្ញុំចេះតែយល់ថាខ្ញុំត្រូវធ្វើតាមបង្គាប់នាងទាំងអស់, បើនាងចង់សម្លាប់ខ្ញុំ ខ្ញុំឃាត់យ៉ាងម្តេចកើត ? នាងចង់ធ្វើអី ខ្ញុំមិនឲ្យធ្វើក្រែងនាងលែងសប្បាយណា៎ !

អាស៊ីរឈរស្តាប់ភ្លេចភ្លាំងស្មារតីនឹកថានេះជាពាក្យពិតបរិសុទ្ធ ដែលហូរចេញពីទឹកចិត្តស្មោះត្រង់របស់នាយមែន ។ នាងរំភើបណាស់ក្រហមមុខចង់យំម្តងទៀត ។

នាងខំទប់សួរទៀត:

- ហេតុអី... បងល្អនឹងខ្ញុំម្ល៉េះ ?

- ធ្វើអ្វីក៏ដោយឲ្យតែអ្នកនាងសប្បាយខ្ញុំសប្បាយដែរ ។ នាងអាស៊ីរ ... ខ្ញុំចង់តែឈរសម្លឹងនាងមួយថ្ងៃរាល់ល្ងាចរហូតទៅ ។

វាចានេះហូរចេញពីបេះដូងត្រង់ៗ តែម្តង ។ អាស៊ីរអាយុតិចមែនតែនាងធ្លាប់រស់នៅជាមួយមនុស្សគ្រប់ពូជនាងធ្លាប់ស្គាល់ ធ្លាប់ឮការច្រើនមិនល្អដូចមាណពដែលរស់ក្នុងព្រៃភ្នំតាំងពីតូចទេ ។ នាងយល់ថានេះជាពាក្យផ្តោះផ្តងដើម្បីសំដែងទឹកចិត្តស្នេហាបរិសុទ្ធរវាងបុរសនិងស្ត្រី ។ កាលបើយល់ចិត្តមាណពចង់រួមរក្សាជាមួយនាងអស់មួយជីវិត, នាងក្រមុំអៀនក្រហមដល់គុម្ពត្រចៀក ។ នាងឱនមុខឈ្ងោកជីម្ជូរជាយអាវធ្វើភ្នែកម៉ឺកៗអស់ពេលជាយូរ ។ ទីបំផុតនាងពោលតិចៗ:

Khmer Story Lovers



— ខ្ញុំដឹងហើយថាបងជាមនុស្សល្អណាស់ ។ កាលនៅក្នុងទូក, យើង... យើងមានខ្នើយតែមួយ ... ភួយតែមួយ ... ទោះបីស្លាប់ទៅក៏ខ្ញុំមិនព្រមនៅជាមួយអ្នកណាទៀតដែរ ។

សំដីនេះមានន័យថា ព្រហ្មលិខិតកាត់តែងមកផ្គូផ្គងហើយ ។ អ្នកកម្លោះត្រូវគេបង្ហូចនំអន្សមបោះចូលដល់ខ្នើយ ភួយនាងក្រមុំតែម្តង នៅជិតគ្នាមួយយប់គត់ ក៏ដូចជាទេវតាកាត់តែងឲ្យអ្នកទាំងពីរជួបគ្នាជាគូព្រេងដែរ ។

ប៉ុន្តែនាងជាស្រីក្រមុំ មិនសមនិយាយស្តីបែបនេះចំពោះមុខប្រុសកំលោះ ទើបនាងពោលខ្សាវៗ ស្តាប់មិនចង់ឮ ។ ស៊ីផាននោះល្ងង់យ៉ាងណាក៏អាចយល់ថា នាងក្រមុំពេញចិត្តអារម្មណ៍ជិតចង់នៅជិតខ្លួនដែរ ម៉្លោះហើយនាយរីករាយណាស់ អត់ទ្រាំមិនបានពោលតបវិញ :

— បើនៅលើកោះនេះមានតែគ្នាយើងពីរនាក់ប្រហែលសប្បាយណាស់មែនទេ ? យើងរស់លើកោះនេះរហូតទៅ ប៉ុន្តែគួរស្តាយត្រង់មានក្រុមប៉ាយវ៉ាន់ជាន, តាទីងមិនបី, មិនហួសបួន តាមនាទៅ ធ្វើឲ្យយើងប្រុងប្រយ័ត្នខ្លួនព្រួយបារម្ភទាំងយប់ទាំងថ្ងៃ ។

អាស៊ីវងើបមុខឆ្លើយ :

— ខ្ញុំមិនសូវខ្លាចទីងមិនហួសបី, មិនហួសបួនឬលោកគ្រូប៉ាយទេ, ខ្ញុំខ្លាចតែមួយមុខគត់, ខ្លាចថ្ងៃក្រោយបងសម្លាប់ខ្ញុំ ។

ស៊ីផានកាដៃយ៉ាងប្រញាប់ :

— ទេ ! ខ្ញុំសុខចិត្តសម្លាប់ខ្លួនឯង មិនហ៊ានប៉ះពាល់រូបនាងឡើយ ។

អាស៊ីវលើកដៃម្ខាងមកមើលហាក់ដូចជាភ័យខ្លាចមាណពសម្លាប់នាងដូចការយល់សប្តិមែន ។ ពេលនោះព្រះអាទិត្យបោសរស្មីតាមចន្លោះស្លឹកឈើមកលើដៃនាងក្រមុំ បង្ហាញសាច់ឈាមភ្លឺថ្លាដូចកញ្ចក់ មាណពទ្រាំមិនបានចាប់ដៃនាងក្រមុំថើបខ្សឹតទាំងមិនដឹងខ្លួន ។ អាស៊ីវលាន់មាត់យី ! ដកដៃមកវិញភ្លាម ត្រូវនាងមិនទាន់មានកម្លាំងស្រួលបួលផងក៏ទន់ជើងផ្អែកនឹងគល់ឈើដកដង្ហើមញាប់ស្អក ។ ស៊ីផានស្តាយក្រោយបន្ទោសខ្លួនឯងដែលប្រព្រឹត្តអំពើមិនគប្បីបណ្តាលឲ្យនាងខឹងញាប់ញ័រ ទើបប្រញាប់លន់តួទោស :

— អ្នកនាងអាស៊ីវ, សូមអភ័យទោសឲ្យខ្ញុំផង ។ ខ្ញុំគ្មានបំណងអាក្រក់ទេ, នេះមកពី . . . មកពីខ្ញុំ . . .

## ខណ្ឌទី ២០

## ស្ងប់រវាងស្វាមីស្ត្រី

អាស៊ីវឃើញនាយឃ័យបែកញើស នាងអាណិតណាស់ ដាក់ដៃទន់ល្មួកក្នុងបាតដៃធំមាំរបស់អ្នកកម្លោះហើយពោលទន់ភ្លន់៖

- បងគ្មានធ្វើអ្វីខុសទេ, កុំបាច់សុំទោសតែ ។

ស៊ីផានក្រេកអរជាអនេកបេះដូងលោតកុកកាក់, ក្ដាប់ដៃទន់ត្រជាក់នោះប្រាប់ថ្នមៗឥតហ៊ានបើបទៀតទេ ។

អាស៊ីវដកដង្ហើមសម្រួលវិញ រួចពោល៖

.. បងបានជួយស្រាយជីវិតឲ្យខ្ញុំនិងលោកយាយ មិនដឹងថ្ងៃណាឆ្នាំណា យើងមានកម្លាំងជួបដើមទេ ។

មាណពឃ័យដឹងរឿងគ្រោះថ្នាក់កើតឡើង ដោយសារការហាត់យុទ្ធសិល្បៈខុសទំនង កំមិនហ៊ានបញ្ចេញយោបល់ផ្ដេសផ្ដាស, គ្រាន់តែពោល៖

- បើពួកចិនមិនហួសបួនពួកយើងមិនឃើញ, លោកយាយនិងអ្នកនាងគ្មានកម្លាំងជួបដើម កំឥតទាស់ខុសដែរ ។

អាស៊ីវអស់សំណើច៖

-ម៉េចនៅហៅលោកយាយ, អ្នកនាងទៀត? លោកយាយជាអ្នកបង្កើតក្រុមព្រះកាចិត្យ, បងជាសិស្សច្បងជំនាន់ទីពីរហើយ ម៉េចមិនហៅអ្នកគ្រូយាយម៉ាត់ទៅ?

-ហ៊ឺ! ធ្លាប់ហៅដូច្នេះហើយ, មិនងាយកែប្រែទេអ្នកនាង...

-ហ្នឹងទេ? ហៅអ្នកនាងភ្លាម!

-បាទ១អីចឹងសុំប្រាប់ខ្ញុំផងតើខ្ញុំត្រូវហៅយ៉ាងម៉េច?

ថ្ពាល់អាស៊ីវឡើងពណ៌ក្រហមដូចផ្លែទទាប់ពុំ ។ នាងនឹកថាបងត្រូវហៅខ្ញុំថា «អូន» ព្រោះខ្ញុំហៅ «បង១» តែញមាត់ហើយតើ! ប៉ុន្តែនាងអៀនខ្មាសអៀនជាស្រីក្រមុំដោយតបថា៖

- ហៅខ្ញុំថា អាស៊ីវ១បានហើយ ។ ចុះខ្ញុំត្រូវហៅបងយ៉ាងម៉េចវិញ?

- បងហៅយ៉ាងម៉េចតាមចិត្តចុះ ។

នាងក្រមុំសើច :

- ខ្ញុំហៅបងអន្សមធំ , ខឹងទេ ?

- ហៅចុះល្អណាស់ , ខ្ញុំមិនខឹងទេ ។

អាស៊ីវហៅតិចៗថា : បងអន្សមធំ ! នាយឆ្លើយ :

- បាទអាស៊ីវ ។

អ្នកទាំងពីរសម្លឹងមុខគ្នាញញឹមដោយសប្បាយពេញចិត្ត ។ ស៊ីផានពោលបន្ត :

- នាងឈរយូរហើយ , មកអង្គុយផ្អែកគ្នាលេងប្អូន ។

គេអង្គុយទន្ទឹមគ្នាក្រោមម្លប់ឈើ ។ អាស៊ីវមានសក់វែងប្រះស្មាពណ៌ខ្មៅស្រើប ។ ព្រះអាទិត្យបាំងលើក្រមុំកម្លោះ, ព្រះពាយបោកបក់រំភើយផាយផាត់សក់នាងក្រមុំទៅលើទ្រូងមាណព នាយចាប់កាន់សក់នាងអង្អែលថ្នមៗ, នាងក្រមុំផ្ដើមពោល :

- បងអន្សមធំ, បើមិនជួបបងទេ, ពេកយាយងឹងរូបខ្ញុំច្បាស់ជាស្លាប់តាយហោងក្នុងទន្លេឈានកាន់បាត់ទៅហើយ, មិនមែនបានអង្គុយនិយាយលេងដូចពេលនេះទេ ។

មាណពងក់ក្បាល :

- បើយើងរស់ជាមួយគ្នារបៀបហ្នឹងរហូតទៅមិនស្រួលឬ ? ម៉េចបងខំហាត់យុទ្ធសិល្ប : ឯងវាយយើង, យើងវាយឯង នាំតែទុក្ខវេទនាឥតអំពើល្អ ! ខ្ញុំមិនទាន់យល់សោះទេ ។

- បើរៀនត្រូវបេះគុនវិជ្ជាព្រោះក្នុងលោកនេះមានមនុស្សអាក្រក់ មនុស្សខូចច្រើនណាស់ ។ បើបងមិនវាយគេ, គេមកវាយបងមុនណា ! ហើយបើច្រលំដៃច្រលំជើងសម្លាប់គេទៅ,យើងមិនអាចជួយគេឲ្យរស់វិញបានឡើយ ។ បងអន្សមធំ, ខ្ញុំបងអង្វររឿងមួយ, បងព្រមទេ ?

- ថីក៏មិនព្រម ! ឲ្យតែនាងប្រាប់ ខ្ញុំធ្វើតាមទាំងអស់ ។

- គុនកាំបិតលោកយាយចាំងចិតសិបបីស្ទៀតពូកែមែន , ឲ្យតែហាត់យូររឹតតែស្ទាត់បញ្ចេញមកប្រើការពិតជាគ្មានអ្នកគុននិយមរូបណាយកឈ្នះបានទេ ។ ប៉ុន្តែខ្ញុំបារម្ភបន្តិចព្រោះបងស្លូតត្រង់ពេក, ឯអ្នកគុននិយមទូទៅច្រើនលាក់ពុត អ្នកខ្លះកាចសាហាវក្រៃលែង ។ បើបងពូកែច្បាស់ជាមានសត្រូវច្រើន ម្ល៉ោះហើយអ្នកទាំងនោះតែងតៀតពេលប្រើកលល្បិចបំផ្លាញបងឲ្យតើបប្រទះគ្រោះថ្នាក់មិនលែងឡើយ ។ ហេតុនេះខ្ញុំសុំអង្វរបងឲ្យហើយណា ! ខំចៀសវាងការវិវាទ

Khmer Story Lovers



ដើម្បីផ្ដួលសត្រូវតិចបំផុត ។

ស៊ីផាននឹកក្បាលយល់ស្រប ៖

- នាងចង់ឲ្យខ្ញុំបានសុខ ខ្ញុំត្រូវធ្វើតាមនាងទាំងអស់ ។

កាស៊ីវពោលទាំងទឹកមុខក្រហមព្រឿងៗ ៖

- ថ្ងៃក្រោយកុំចេះតែថាស្លាប់បន្ដាប់ខ្ញុំទាំងអស់អីចឹងទៀតខ្មាសគេណា ! មនុស្សប្រុសអីចឹងគេថា មិនមែនបុរសដើមទ្រូងប្រាំហត្ថទេ , គេសើចរាប់ហើយ ។

នាងឈប់បន្តិចទើបពោលត ៖

- តាមដែលខ្ញុំមើលគុនកាំបិតរបស់លោកយាយ , ខ្ញុំយល់ថាស្នៀតនីមួយៗ កាចសាហាវណាស់ , បើថ្ងៃក្រោយបងយកគម្រិះនេះទៅប្រកួតប្រជែង ឬ ប្រយុទ្ធនឹងគេ បងសម្លាប់មនុស្សក៏ច្រើន , មានសត្រូវក៏ច្រើនដែរ , ខ្ញុំព្រួយណាស់ ។

ស៊ីផានភ្ញាក់ព្រើតពោលភ្លាម ៖

- នាងនិយាយត្រូវមែន ! ខ្ញុំឈប់ហាត់ស្នៀតអស់ហ្នឹងហើយ ។ ចាំសុំលោកយាយឲ្យបង្ហាត់វិជ្ជាអ្វីផ្សេងវិញ ។

កាស៊ីវគ្រវីក្បាល៖

- មិនកើតទេ, ក្រុមព្រះអាទិត្យមានតែគុនកាំបិតមួយមុខនេះគត់ ។ ប៉ុន្តែស្នៀតអ្វីយុទ្ធសិល្បៈអ្វីក៏ដោយ ឲ្យតែប្រើការវាតែងមានមនុស្សរបួសឬស្លាប់ដូច្នេះឯង, បើសម្លាប់គេមិនបានវាអស់មានឈ្មោះ ថាវិជ្ជាគុនហើយ ។ ខ្ញុំសុំឲ្យបងមានធម៌មេត្តាសន្ដោសប្រណីគេតែប៉ុណ្ណោះ បានហើយ, សុំបងចាំពាក្យខ្ញុំមួយម៉ាត់នេះគ្រប់ពេលប្រយុទ្ធគ្នាណា ! បើអាចជៀសវាងបាន,ត្រូវសន្ដោស ។

មាណពថាតាម ៖

- បើអាចជៀសវាងបានត្រូវសន្ដោស ។ យី ! ពាក្យនេះត្រូវណាស់, កាស៊ីវម៉េចនាងឆ្លាតម្ល៉េះចេះរកពាក្យពីរោះមកនិយាយ ?

កាស៊ីវញញឹម៖

- ខ្ញុំមិនមែនឆ្លាតរកនឹកពាក្យពីរោះនិយាយខ្លួនឯងទេ ។ នេះជាកំណាព្យមានន័យថា «ចេញពី

ក្លូមកគ្មានគូប្រៀបផ្ទឹម, បើការចៀសវាងត្រូវសន្តោស» ។

- យី ! អ្វីទៅដែលគេហៅកំណាព្យនោះ ?

ត្បិតស៊ីផាងគ្មានចេះអក្សរបន្តិចណាសោះ, នាយមិនស្គាល់កំណាព្យកាព្យឃ្លោងជាអ្វីទេ ។ អាស៊ីវមើលមុខអ្នកកម្លោះយ៉ាងបំភ្លេកមិនជឿថានាយមិនស្គាល់មែនឬសួរលេង, ម៉្លោះហើយនាងមិនឆ្លើយ ធ្វើជាសញ្ជឹងគិតបន្តិចទើបតប :

- ទាល់តែមានឥទ្ធិពលខ្លាំងក្លាគ្មាននរណាប្រៀបផ្ទឹមបានទើបអាចធ្វើតាមកំណាព្យ ដែលថាចៀសវាងបានត្រូវសន្តោស ។ បើមិនដូច្នេះទេ, យើងសុំអង្វរគេ «អនិសាច» សម្បើមណាស់បងអន្សមធំ . . .

នាងញញឹមបន្តិច :

- ហៅបង ៗ ទទេបានហើយហ្ន៎ ! ហៅបងអន្សមធំគ្មានក្បាលគ្មានកន្ទុយអីចឹងពិបាកណាស់ ៗ ខ្ញុំចង់ឲ្យបងចេះសន្តោសអ្នកដទៃផង, តែបងត្រូវមើលឲ្យមែនទែន, អ្នកគុននិយមការគេច្រើនតែងលាក់ពុត ។ កាលណាឃើញបងចិត្តល្អស្មោះត្រង់ គេអាចឆ្លៀតឱកាសដែលបងប្រហែសធ្វេសខ្លួនសម្លាប់ឬធ្វើបាបបងដោយប្រការណាផ្សេងៗ ។ ហេតុនេះខ្ញុំយល់ថា . . . ខ្ញុំចេះយុទ្ធសិល្បៈមួយស្នៀតបែបពូកែគ្រាន់បើដែរ, ចាំខ្ញុំធ្វើកាយវិការឲ្យបងមើលសិន ។

នាងកាន់កាំបិតកាប់ឧសកញ្ចាស់ហើយក្រោកឈរធ្វើបលនាយតៗ ដោយយាវទៅមុខរួចបំបែរមុខកាំបិតគ្រវាសទៅម្ខាងព្រមទាំងបំពេនកម្លាំងលើកសំពងចុះមក ។ មាណពសម្ងំនាងក្រមុំតាំងពីអាវត្រូវខ្យល់ផាយផាត់រហូតដៃជើងលើកល្វតល្វន់នាយនឹកថា មិនស្មានទាន់អាស៊ីវអាចបញ្ចេញស្នៀតគុនដ៏អស្ចារ្យបែបនេះសោះ ។ នាយឈរសម្ងំរូបរាងនាងក្រមុំដោយឥតចង់បាំកាយវិការមួយណាសោះ រហូតអាស៊ីវថយក្រោយពីរជំហានលើកកាំបិតទន្ទឹមទ្រូងប្រាប់ថា :

- លុះដកកាំបិតឈរស្ងៀមដូច្នេះហើយ, យើងត្រូវរក្សាកម្លាំងជាតុដដែល ការពារដើមទ្រូងទាំងមុខទាំងក្រោយ ទាំងឆ្វេងទាំងស្តាំប្រាជ្ញាកុំឲ្យសត្រូវលបវាយធ្លាក់បាន ។

ពេលចប់នាងបែរមើលស៊ីផាងឃើញនាយឈរសម្ងំធ្លាំងហាក់គ្មានយកចិត្តទុកដាក់សោះក៏សួរ :

- យ៉ាងម៉េចបង ? ស្នៀតនេះមិនប្រសើរទេឬ ?

មាណពក្រហមមុខតបយ៉ាងប្រញាប់ :

អេ, ប្រសើរណាស់, ល្អណាស់ ។

ប្រសើរគ្រាន់ណា, ល្អគ្រាន់ណា ?

ស៊ីផានមុខក្រហមចំអាំងឆ្លើយបាន តែ នែ.. នែ...

កេស៊ីវបន្ទោស :

– ខ្ញុំដឹងហើយ ! បងជាសិស្សច្បងនៃក្រុមព្រះអាទិត្យ ប្រហែលមិនចូលចិត្តមើលស្នៀតគុនរបស់នារីទន់ខ្សោយដូចរូបខ្ញុំទេ ។

មាណពតតិយមួយរំពេច :

– អត់ទោស...ខ្ញុំឃើញនាង...ល្អមើលពេក...ភ្លេចស្នៀតគុនកាំបិតរបស់រលីង ។ អ្នកនាង... អ្នកនាង .សូមជួយបង្ហាញម្តងទៀតមក ។

កេស៊ីវធ្វើជាខឹង :

– ឈប់បង្ហាញហើយ !

មាណពលំអោនកាយគោរពភ្លាម :

– ខ្ញុំសូមអង្វរ អ្នកនាងបង្ហាញម្តងទៀតមក ។

កេស៊ីវញញឹម :

– បាន ! ខ្ញុំសំដែងតែម្តងទៀតទេណា, គ្មានកម្លាំងបង្ហាញជាលើកទីបីឡើយ ។

ពេលនេះនាងកាន់កាំបិតលើកកាបរំម ។ តែយឺតជាងមុនបង្ហាញនាយម្តងទៀត ។ ស៊ីផានទំ តាំងស្មារតីពិនិត្យកាយវិការ និង ចលនាកាំបិតដោយផ្ចិតផ្ចង់ ហើយចេះចាំទាំងអស់ ។ បន្ទាប់មកនាយទទួលកាំបិតពីដៃនាងក្រមុំមកធ្វើគ្រាប់តាមត្រឹមត្រូវឥតខ្ចោះ ។ កេស៊ីវពេញចិត្តណាស់ ពោលពាក្យសរសើរ:

– បងប្រុសឆ្លាតហើយឆាប់ចេះឆាប់ចាំណាស់, ហាត់មួយថ្ងៃតចេះចាំភ្លាម ។ ស្នៀតមួយនេះ ឈ្មោះថា « ស្ទង់ភ្លេងស្ពាបស្ពាំ », ឲ្យតែមុខកាំបិតទៅដល់ណា កម្លាំងជាតុយើងក៏ទៅតាមដល់នោះដែរ ។

(នៅមានត)

ពិគល់ទុកតាមលេខ ៣២៧ ចុះថ្ងៃទី ២៤-៩-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers